# គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង

**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ**

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍* *ថ្ងៃសុក្រ ទី២៧ ខែមីនា ឆ្នាំ២០០៩* *ព្រឹត្តិប័ត្រលេខ០៧៨ ឆ្នាំទី២*



| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| - ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ចុះជួបសំណេះសំណាលជាមួយ ប្រជាពលរដ្ឋនៅខេត្តកណ្តាល | ១ |
| - ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ចុះជួបសំណេះសំណាលជាមួយ ប្រជាពលរដ្ឋនៅខេត្តព្រៃវែង | ២ |
| - ប្រជាពលរដ្ឋមកពីខេត្តឧត្តរមានជ័យ ឈរតវ៉ានៅមុខផ្ទះនាយករដ្ឋមន្ត្រី សុំអន្តរាគមន៍រឿងដីធ្លី | ៣ |
| - សេចក្តីថ្លែងការណ៍ | ៣ |
| - លិខិតរំលែកទុក្ខ | ៤ |


## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅខេត្តកណ្តាល

គោលការណ៍គណបក្សសិទ្ធិមនុស្ស នៅពេលឈ្នះឆ្នោតដឹកនាំរដ្ឋាភិបាល គឺជួយយុវជនអោយមានការងារធ្វើឱ្យមានចំណេះវិជ្ជា និងជួយកូនអ្នកក្រឱ្យរៀនដូចកូនអ្នកមាន បើកូនអ្នកក្រ អត់លុយរៀន គឺរដ្ឋត្រូវរកវិធីដោះស្រាយដើម្បីឱ្យកូនអ្នកក្រអាចមានលទ្ធភាពរៀនសូត្រដូចកូនអ្នកមាន ប៉ុន្តែឥឡូវនេះយុវជនមិនទាន់ទទួលពត៌មានពីយើងបានគ្រប់គ្រាន់ ពោលគឺទទួលបានពត៌មានតិចនៅឡើយ ។ ដូច្នេះយើងត្រូវការពេលវេលាតស៊ូបន្តទៀតដើម្បីអនាគតកូនចៅរបស់យើងជំនាន់ក្រោយ ។ នេះជាប្រសាសន៍លើកឡើងរបស់លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស ដែលលោកបានថ្លែងទៅកាន់សកម្មជន អ្នកគាំទ្រគណបក្សសិទ្ធិមនុស្ស នៅភូមិព្រែកអញ្ចាញ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ។

លោក **កឹម សុខា** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាមបានគូសបញ្ជាក់ទៀថា ប្រសិនបើអ្នកដឹកនាំបច្ចុប្បន្ន ឬ គណបក្សកាន់អំណាចមានគោលការច្បាស់លាស់ធានាអនាគតកូនចៅរបស់យើងឱ្យបានច្បាស់លាស់រឿងនេះមិនថ្វីទេ ប៉ុន្តែលោកមើលឃើញថាគណបក្សកាន់អំណាចមិនបានធានាទេ កូនចៅរបស់យើងកាន់តែអត់ការងារធ្វើកាន់តែច្រើន ចំណែកចាស់ជរាមិនមានការជួយគិតគូរពីបញ្ហាសុខភាព និងបង់ថ្លៃសេវាសុខភាពជូនពួកគាត់នោះទេ ។

លោក **កឹម សុខា** បានបញ្ជាក់បន្ថែមថា បងប្អូនខ្មែរនៅគណបក្សនយោបាយណាក៏ដោយ យើងត្រូវតែរួបរួមគ្នា សាមគ្គីគ្នាដើម្បីការពារអធិបតេយ្យភាពបូរណភាពទឹកដី ដើម្បីធានាឱ្យបាននូវនិរន្តភាពនៃសម្បត្តិធម្មជាតិយើង នឹងធ្វើឱ្យប្រជាពលរដ្ឋទទួលបាននូវភាពស្មើគ្នាចំពោះមុខច្បាប់ដូចប្រជាពលរដ្ឋនៅប្រទេសគេ ។

លោកបានសង្កត់ធ្ងន់ធ្ងរថា ប្រទេសគេហេតុអ្វីបានជារីកចំរើនហើយប្រទេសកម្ពុជាមានប្រជាពលរដ្ឋតែ១៤លាននាក់សោះ ហេតុអ្វីបានជាមិនរីកចំរើន ។ កត្តានេះផ្តើមឡើងដោយហេតុផល ៣យ៉ាង ទី១: គឺអាស្រ័យលើលក្ខណៈសម្បត្តិអ្នកដឹកនាំ ទី២: ពាក់ព័ន្ធនឹងប្រជាពលរដ្ឋ និងទី៣: ទាក់ទងនឹងស្ថានភាពភូមិសាស្ត្រ ប្រវត្តិសាស្ត្រ និងធនធានធម្មជាតិ ។

សកម្មជនសិទ្ធិមនុស្សនៅឃុំព្រែកដំបង ស្រុកមុខកំពូល បានឱ្យដឹងថា ពិធីសំណេះសំណាលនេះមានប្រជាពលរដ្ឋនៅឃុំរបស់លោកចង់ចូលរួមជាច្រើន ប៉ុន្តែបងប្អូនខ្វះខាតមធ្យោបាយធ្វើដំណើរយ៉ាងណាក៏ដោយប្រជាពលរដ្ឋ នៅតែគាំទ្រគណបក្សសិទ្ធិមនុស្ស តែពួកគាត់នៅតែមានការខ្លាចខាងអាជ្ញាធរមូលដ្ឋាន ។

សកម្មជនព្រែកអញ្ចាញ ស្រុកមុខកំពូល បាននិយាយថា នៅឃុំរបស់លោកអាជ្ញាធរភូមិឃុំ នៅតែប្រកាន់ភាពរើសអើង នៅពេលប្រជាពលរដ្ឋ ដែលមាននិន្នាការគាំទ្រគណបក្សផ្សេងពីគណបក្សប្រជាជនកម្ពុជា ទៅពឹងពាក់កិច្ចការអ្វីមួយ អាជ្ញាធរទាំងនោះតែងតែព្រងើយកន្តើយ ។ លោកបានបញ្ជាក់ថាអាជ្ញាធរនៅឃុំព្រែកអញ្ចាញនៅពេលប្រជាពលរដ្ឋ ពឹងពាក់កិច្ចការផ្សេងៗច្រើន តែទារលុយកាក់ ។

សកម្មជនគណបក្សសិទ្ធិមនុស្ស នៅឃុំព្រែកអញ្ចាញបាន អ៊ះអាងទៀតថា ឥឡូវនេះប្រជាពលរដ្ឋនៅឃុំព្រែកអញ្ចាញកាន់តែយល់ដឹងអំពីសភាពការណ៍នយោបាយ នៃគណបក្សកាន់អំណាច និងគណបក្សសិទ្ធិមនុស្ស មានសភាពខុសគ្នាម៉្លោះធ្វើអោយប្រជាពលរដ្ឋមានការគាំទ្រគណបក្សសិទ្ធិមនុស្សកាន់តែច្រើន ពោលគឺខុសពីមុនបើទោះបីជាខ្លាចការគំរាមកំហែងពីអាជ្ញាធរដែនដី ។

## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះជួប សំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅខេត្តព្រៃវែង

ព្រឹកថ្ងៃទី២១ ខែមីនា ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សក្រោមវត្តមានដ៏ខ្ពង់ខ្ពស់ លោក **កឹម សុខា** ប្រធានគណបក្សបានចុះជួបសំណេះសំណាលបងប្អូនប្រជាបលរដ្ឋ នៅភូមិត្រពាំងស្គន់ ឃុំជីផុច ស្រុកមេសាង និងនៅភូមិត្រើយ ឃុំអន្សោង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

ប្រធានប្រតិបត្តិស្រុកមេសាង របស់គណបក្សសិទ្ធិមនុស្សបានឱ្យដឹងថា មានប្រជាពលរដ្ឋសកម្មជនគណបក្សសិទ្ធិមនុស្សជាច្រើននាក់បានមកពីឃុំទាំង៨ក្នុងស្រុកមេសាង ដើម្បីស្តាប់ប្រសាសន៍របស់ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ។ រហូតមកដល់ពេលនេះប្រជាពលរដ្ឋនៅតែមានទឹកចិត្តគាំទ្រគណបក្សសិទ្ធិមនុស្ស ហើយនឹងបន្ថែមការគាំទ្របន្តទៀត នៅពេលដែលគណបក្សសិទ្ធិមនុស្សចងសម្ព័ន្ធភាព ជាមួយគណបក្សសម រង្ស៊ី ដែលចំណុចនេះត្រូវបានប្រជាពលរដ្ឋមើលឃើញថា ជាកំលាំងចលករដ៏ខ្លាំងមួយនៃលទ្ធិប្រជាធិបតេយ្យដើម្បីផ្លាស់ប្តូរបែបកុម្មុយនីស្ត ។

ម្យ៉ាងទៀតប្រជាពលរដ្ឋនៅតែមើលឃើញថា គណបក្សសិទ្ធិមនុស្សមានគោលការច្បាស់លាស់ដូចជា ជួយចាស់ជរា ឱ្យមានប្រាក់ឧបត្ថម្ភ៤0000រៀលក្នុង១ខែ កូនអ្នកក្រអាចរៀនសូត្របានវែងឆ្ងាយ ព្យាបាលសុខភាពជូនប្រជាពលរដ្ឋ មិនគិតថ្លៃនេះប្រសិនបើគណបក្សសិទ្ធិមនុស្សដឹកនាំរដ្ឋាភិបាល ។

ប្រធានប្រតិបត្តិស្រុកមេសាងរូបនេះបានបញ្ជាក់បន្ថែមថា អាជ្ញាធរភូមិ ឃុំ ស្រុកមេសាង ក្នុងខេត្តព្រៃវែងនៅតែប្រកាន់គំនិតរើសអើងចំពោះប្រជាពលរដ្ឋ ។ លោកមើលឃើញថា អាជ្ញាធរមូលដ្ឋានប្រកាន់បក្ខពួកពារបៀបនេះ ធ្វើឱ្យខ្មែរមើលមុខគ្នាមិនចំ បែកបាក់សាមគ្គីភាព និងការដើរថយក្រោយនៃលទ្ធិប្រជា

ធិបតេយ្យ ។ ចំណែកឯតំណាងគណបក្សសិទ្ធិមនុស្សប្រចាំឃុំជីធុចបានឱ្យដឹងថាអាជ្ញាធរក្នុងឃុំជីធុច មានការរើសអើងគណបក្សនយោបាយ និងគាបសង្កត់ប្រជាពលរដ្ឋខ្មែរ ។ ការរើសអើងនេះអាស្រ័យដោយអាជ្ញាធរមានការព្រួយបារម្ភ ពីព្រោះប្រជាពលរដ្ឋនិយមគាំទ្រគណបក្សសិទ្ធិមនុស្ស និងគណបក្សសម រង្ស៊ី ។

## ប្រជាពលរដ្ឋមកពីខេត្តឧត្តរមានជ័យឈរតវ៉ានៅមុខផ្ទះនាយករដ្ឋមន្ត្រីសុំអន្តរាគមន៍រឿងដីធ្លី

ប្រជាពលរដ្ឋ៥៣គ្រួសារ ក្នុងចំណោមប្រជាពលរដ្ឋ២៧៤គ្រួសារនៅភូមិបុស្ស ឃុំកូនគ្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យបានមកតវ៉ានៅមុខគេហដ្ឋានលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នាក្រុងតាខ្មៅ ខេត្តកណ្ដាល ដើម្បីឱ្យលោកនាយករដ្ឋមន្ត្រី ជួយអន្តរាគមន៍ដល់ក្រុមហ៊ុនអង្គរស៊ូតើ ដែលបានឈូសឆាយដីធ្លី និងដុតលំនៅដ្ឋានរបស់ពួកគាត់ ។

លោក **សារិន** អ្នកភូមិបុស្ស ឃុំកូនគ្រៀលដែលគាត់បានតវ៉ានៅមុខគេហដ្ឋានប្រមុខរដ្ឋាភិបាលបានរៀបរាប់ថា ក្រុមហ៊ុនអង្គរសូតើបានឈូសឆាយដីធ្លី ប្រជាពលរដ្ឋចំនួន១៥០០ហិកតាថាប្រភេទដីធ្លី និង ដីលំនៅដ្ឋាន។

ដីធ្លីនោះប្រជាពលរដ្ឋកាន់កាប់តាំងពីឆ្នាំ២០០៣ ហើយក៏មានការទទួលស្គាល់ពីមេភូមិចាស់ ដែលវាស់វែងបែងចែកឱ្យអ្នកភូមិប្រកបរបររកស៊ីស្រែចំការ ហើយបងប្អូនខ្លះលោកមានបង្កាន់ដៃកាន់កាប់ដីធ្លី ប៉ុន្តែក្រុមហ៊ុននៅតែចាប់ផ្ដើមឈូសឆាយដីធ្លីប្រជាកសិករ ។

អ្នកភូមិរូបនេះបានបន្តទៀតថា ក្រោយពីការឈូសឆាយដីស្រែរួចហើយគេបន្តឈូសឆាយដីលំនៅដ្ឋាន និងដុតបំផ្លាញផ្ទះសំបែងប្រជាពលរដ្ឋជាង១០០ខ្នង ។ ពាក់ព័ន្ធនឹងករណីវិវាទដីធ្លីនេះដែរអ្នកភូមិបានប្ដឹងប្ដល់ដល់អាជ្ញាធរស្រុក ខេត្តប៉ុន្តែមិនមានដំណោះស្រាយទាល់តែសោះ ។

ស្ត្រីវ័យ៤២ឆ្នាំ នៅភូមិបុស្ស ឃុំកូនគ្រៀលបានគូសបញ្ជាក់ថា ដីស្រែចំការរបស់គាត់មាន ៥ហិកតា និងដីឡូត៍ផ្ទះក្បាល៣០ម៉ែត្រ និងបណ្ដោយ៤០ម៉ែត្រ ក្រោយពីមានការដុតបំផ្លាញលំនៅដ្ឋានពួកគាត់ក៏បានមករស់នៅផ្ទុំគ្នា ។

លោកស្រី **ណារ៉េន** អ្នកសំរបសំរួលសមាគមអាដហុកនៅខេត្តឧត្តរមានជ័យបានបញ្ជាក់បន្ថែមថា ដំណោះស្រាយរបស់ក្រុមហ៊ុនអង្គរស៊ូតើ ពីប្រជាពលរដ្ឋមិនអាចទទួលយកបានទេពីព្រោះមានប្រជាពលរដ្ឋមួយចំនួនរស់នៅយូរយារ និងមួយចំនួនទៀតក៏ទើបតែមកតាំងទីលំនៅថ្មីផងដែរ ។ លោកថាការដោះស្រាយរបស់ក្រុមហ៊ុន និងអាជ្ញាធរជាមួយប្រជាពលរដ្ឋមានសភាពយឺតយ៉ាវរហូតមានក្រុមសមត្ថកិច្ចបានទៅរុះរើខ្ទមរបស់ពួកគាត់ ។

លោក **ពេជ្រ សុឃិន** អភិបាលខេត្តឧត្តរមានជ័យបានមានប្រសាសន៍ថា អាជ្ញាធរខេត្តបានដោះស្រាយជូនប្រជាពលរដ្ឋរាប់រយគ្រួសាររួចហើយពោលគឺនៅសល់តែ១២គ្រួសារប៉ុណ្ណោះ ដែលមិនបង្ហាញមុខ និងអាជ្ញាធរខេត្តបានដោះស្រាយឱ្យដីប្រជាពលរដ្ឋ និងប្រាក់សំណងមួយចំនួនអាស្រ័យលើទំហំដីធ្លី ។

សូមបញ្ជាក់ទាក់ទងរឿងទំនាស់ដីធ្លីនេះ លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្សធ្លាប់មានប្រសាសន៍ថា គណបក្សប្រជាជនកម្ពុជាបរាជ័យក្នុងការដោះស្រាយទំនាស់ដីធ្លី ។

*ភ្នំពេញ, ថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០០៩*

## សេចក្ដីថ្លែងការណ៍

**គណបក្សសិទ្ធិមនុស្ស** មានសេចក្ដីក្រៀមក្រំយ៉ាងខ្លាំងក្រោយពីបានទទួលពត៌មានថាលោក **ស៊ឹម ឈេត** អាយុ៤៨ឆ្នាំ ដែលជាសកម្មជនដ៏មានប្រជាប្រិយរបស់គណបក្សសិទ្ធិមនុស្សនៅឃុំកណ្ដុរជ្រំ ស្រុកពញាក្រែក ខេត្តកំពង់ចាម បាន

ត្រូវឃាតករបាញ់សំលាប់យ៉ាងឃោរឃៅទៅលើរូបលោក កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោងប្រមាណ១២យប់ ខណៈដែលគាត់កំពុងជិះម៉ូតូតាមដងផ្លូវធ្វើដំណើរទៅផ្ទះគាត់ ។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា នេះជាអំពើឃាតកម្មយ៉ាងសាហាវ ព្រៃផ្សៃដែលបានរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានសន្តិសុខផ្ទាល់ខ្លួនរបស់បុគ្គល និងសិទ្ធិនយោបាយរបស់លោក **ស៊ឹម ណោត** ។ មិនតែប៉ុណ្ណោះឃាតកម្មនេះបានបង្កឱ្យមានការភ័យខ្លាចនៅក្នុងអារម្មណ៍សកម្មជននយោបាយក៏ ដូចជាប្រជាពលរដ្ឋខ្មែរទូទៅផងដែរ ។

**គណបក្សសិទ្ធិមនុស្ស** ថ្កោលទោសយ៉ាងខ្លាំងចំពោះក្រុមឃាតករ និងអ្នកសមគំនិត និងសូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ច ស្វែងរកចាប់ឃាតករពិតឱ្យបានដើម្បីផ្តន្ទាទោសរកយុត្តិធម៌ជូនជនរងគ្រោះ និងគ្រួសារព្រមទាំងបំបាត់ចោលឱ្យអស់នូវទម្រង់និទណ្ឌភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លិខិតចូលរួមរំលែកមរណទុក្ខ លោកស្រីភរិយាសពលោក ស៊ឹម ណោត និងក្រុមគ្រួសារ

ក្នុងនាមថ្នាក់ដឹកនាំសមាជិក សមាជិការបស់ **គណបក្សសិទ្ធិមនុស្ស** ទាំងក្នុង និងក្រៅប្រទេស និង ក្នុងនាមខ្ញុំផ្ទាល់ យើងខ្ញុំទាំងអស់មានសេចក្តីទុក្ខសោកក្រៀមក្រំ យ៉ាងខ្លាំងក្រោយពីបានទទួលពត៌មានថា លោក **ស៊ឹម ណោត** ជាសកម្មជនដ៏ឆ្នើមរបស់គណបក្សសិទ្ធិមនុស្សបានទទួលមរណភាព ដោយការបាញ់ប្រហារពីក្រុមឃាតករដ៏ ឃោរឃៅកាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ នៅវេលាម៉ោងប្រមាណ១២យប់ ខណៈដែលគាត់កំពុងជិះម៉ូតូនៅតាម ដងផ្លូវត្រឡប់ទៅផ្ទះវិញ ។

មរណភាពរបស់លោក **ស៊ឹម ណោត** គឺជាការបាត់បង់ស្វាមី ឪពុក បងប្អូនដ៏ឧត្តមនៃក្រុមគ្រួសារលោក ស្រីក៏ដូចជាគណបក្សសិទ្ធិមនុស្សទាំងមូល ។

### គ្រួសារសពជាទីគោរព !

**គណបក្សសិទ្ធិមនុស្ស** ចាត់ទុករូបលោក **ស៊ឹម ណោត** ជាសមាជិកសកម្មដ៏ឆ្នើម អង់អាច ក្លាហាន និងស្មោះត្រង់ចំពោះជាតិ មាតុភូមិ ដែលរូបខ្ញុំក្តី សមាជិកឯទៀតក្តីចងចាំនូវគុណូបការៈរបស់លោក ហើយប្តេជ្ញាបន្តការតស៊ូដើម្បីសេរីភាព និងលទ្ធិប្រជាធិបតេយ្យដែលជាក្តីប្រាថ្នារបស់លោកឱ្យបានសំរេច ។ យើងខ្ញុំសូមបួងសួងឱ្យវិញ្ញាណក្ខ័ន្ធរបស់លោក **ស៊ឹម ណោត** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកស្រី បុត្រ និងក្រុមគ្រួសារលោក **ស៊ឹម ណោត** ទាំងអស់មេត្តាទទួលនូវការគោរព និងការរំលែកទុក្ខអំពីយើងខ្ញុំទាំងអស់គ្នា ។


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខៈ ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ វណ្ណា | ទូរស័ព្ទលេខៈ ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**វប្បធម៌និទណ្ឌភាពនឹងត្រូវលុបបំបាត់ចោលពេលគណបក្សសិទ្ធិមនុស្សឈ្នះឆ្នោត !**